# សេចក្តីជូនដំណឹង
# ស្តីពី មហាសន្និបាតភាគហ៊ុនិក
# របស់ក្រុមហ៊ុន ពីកាសូ ស៊ីធី ហ្គាដិន ឌីវេឡុបមិន ម.ក

ក្រុមហ៊ុន ពីកាសូ ស៊ីធី ហ្គាដិន ឌីវេឡុបមិន ម.ក ("ព.ស.ហ") មានកិត្តិយស សូមជម្រាបជូនដំណឹងដល់សាធារណៈជន និងវិនិយោគិនទាំងអស់ឱ្យបានជ្រាបថា៖ យោងតាមសេចក្តីសម្រេចក្នុងការប្រជុំរបស់ក្រុមប្រឹក្សាភិបាល នៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៦ ក្រុមហ៊ុននឹងរៀបចំមហាសន្និបាតភាគហ៊ុនិកដោយផ្ទាល់ តាមកាលបរិច្ឆេទកំណត់ដូចខាងក្រោម៖

១. ប្រភេទនៃការប្រជុំភាគហ៊ុនិក៖ មហាសន្និបាតភាគហ៊ុនិកសាមញ្ញ (សាមញ្ញ)

២. កាលបរិច្ឆេទកំណត់ទុក៖ ថ្ងៃទី១៧ ខែ មីនា ឆ្នាំ២០២៦

៣. កាលបរិច្ឆេទអិចឆាយឋ៍៖ ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៦

៤. កាលបរិច្ឆេទនិងពេលវេលាប្រជុំ៖ ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៦ ចាប់ផ្តើមពីម៉ោង ៨:០០ នាទីព្រឹក

៥. ទីកន្លែងប្រជុំ៖ ប្រជុំដោយផ្ទាល់ (នៅអគារ ពីកាសូ ស៊ីធី ហ្គាដិន, ជាន់R)

៦. របៀបវារៈនៃកិច្ចប្រជុំ៖

| របៀបវារៈ | ម៉ោង |
|---|---|
| ១. ការចុះឈ្មោះភាគហ៊ុនិក | ០៨:០០ - ០៨:៣០ នាទីព្រឹក |
| ២. ការគោរពភ្លេងជាតិ | ០៨:៣០ - ០៨:៣៥ នាទីព្រឹក |
| ៣. ការបើកកិច្ចប្រជុំ<br>៣.១ មតិស្វាគមន៍របស់លោកស្រី Teoh Seok Ai នាយកប្រតិបត្តិនៃក្រុមហ៊ុន ពីកាសូ ស៊ីធី ហ្គាដិន ឌីវេឡុបមិន ម.ក<br>៣.២ ការណែនាំអំពីប្រធានក្រុមប្រឹក្សាភិបាល<br>• ការពន្យល់អំពីការលាលែងពីតំណែងរបស់សមាជិកក្រុមប្រឹក្សាភិបាល<br>• ការបញ្ជាក់អំពីសមាសភាពក្រុមប្រឹក្សាភិបាលដែលមានសមាជិកចំនួន ៣ (បី) រូប នាពេលបច្ចុប្បន្ន<br>៣.៣ បទបង្ហាញពីរបាយការណ៍លទ្ធផលអាជីវកម្មប្រចាំឆ្នាំ២០២៥<br>ក. របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំសម្រាប់ឆ្នាំដែលបានបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥<br>ខ. ផែនការអភិវឌ្ឍន៍អាជីវកម្មរបស់ក្រុមហ៊ុន<br>- ការចាប់ផ្តើមគម្រោង និងផែនការយុទ្ធសាស្ត្រ<br>- ការធ្វើបច្ចុប្បន្នភាពអាជីវកម្មផ្សេងៗ | ០៨:៣៥ - ០៩:៣៥ នាទីព្រឹក |

| របៀបវារៈ | ម៉ោង |
|---|---|
| **៤. ចំណុចដែលត្រូវសម្រេច និងកម្មវិធីសំណួរចម្លើយ**<br>ក.ការអនុម័តលើការបែងចែកភាគលាភដែលបានជានា សម្រាប់រយៈពេលរហូតដល់អង្គមហាសន្និបាតម្ចាស់ភាគហ៊ុនិកលើកក្រោយ។<br>ខ.ការអនុម័តលើការធ្វើបច្ចុប្បន្នភាពនៃលក្ខន្តិកៈក្រុមហ៊ុន ពាក់ព័ន្ធនឹង៖<br>• ការផ្លាស់ប្តូរសមាជិននៃក្រុមប្រឹក្សាភិបាល; និង<br>• ការធ្វើបច្ចុប្បន្នភាពលើរចនាសម្ព័ន្ធភាគហ៊ុនរបស់ក្រុមហ៊ុន។<br>គ.ការអនុម័តលើប្រាក់បំណាច់មានចំនួនសរុប ១០៨,០០០ ដុល្លារអាមេរិក សម្រាប់សមាជិកក្រុមប្រឹក្សាភិបាលទាំង ៣ (បី) រូប សម្រាប់ឆ្នាំ២០២៦ ដែលមានប្រសិទ្ធភាពចាប់ពីថ្ងៃទី០១ ខែឧសភា ឆ្នាំ ២០២៦ តទៅ។<br>ឃ.ការអនុម័តលើការរៀបចំការទូទាត់សម្រាប់ការទិញដីគម្រោងពីកាសូ២។<br>ង.ការអនុម័តលើការលក់ចេញភាគហ៊ុនរបស់ក្រុមហ៊ុនដែលមាននៅក្នុងក្រុមហ៊ុន ឈីបូឌា ខនស្រ្តាក់សិន ឯ.ក ដែលបច្ចុប្បន្នមិនមានសកម្មភាពអាជីវកម្ម។<br>ច.កម្មវិធីសំណួរ និងចម្លើយ។<br>ឆ.ការប្រកាសលទ្ធផលនៃការបោះឆ្នោត។ | ០៩:៣៥ - ១១:០០ នាទីព្រឹក |
| **៥. ការបញ្ចប់កិច្ចប្រជុំ**<br>បិទកិច្ចប្រជុំដោយ លោកស្រី Teoh Seok Ai នាយកប្រតិបត្តិ នៃក្រុមហ៊ុន ពីកាសូ ស៊ីធី ហ្គាដិន ឌីវេឡុបមិន ម.ក ។ | ១១:០០ - ១១:១០ នាទីព្រឹក |

**កំណត់សម្គាល់៖**

- ភាគហ៊ុនិកមានសិទ្ធិចូលរួមប្រជុំមហាសន្និបាតភាគហ៊ុនិកដូចបានកំណត់ខាងលើនេះ ជាភាគហ៊ុនិកដែលមានឈ្មោះនៅក្នុងបញ្ជីឈ្មោះ ផ្លូវការ ដោយទទួលបានពីបញ្ជីឈ្មោះភាគហ៊ុនិកដែលរៀបចំឡើង នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ ២០២៦។
- ភាគហ៊ុនិកដែលមានឈ្មោះនៅក្នុងបញ្ជីឈ្មោះភាគហ៊ុនិកនៅកាលបរិច្ឆេទកំណត់ទុក ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៦ នឹងទទួលបាននូវលិខិតអញ្ជើញតាមមធ្យោបាយអេឡិចត្រូនិក ពីភ្នាក់ងារ ផ្ទេរមូលបត្រ របស់ធនាគារ អេស៊ីលីដា។
- ភាគហ៊ុនិកដែលធ្វើការ **លក់** មូលបត្រកម្មសិទ្ធិរបស់ខ្លួន នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៦ **នៅតែមានសិទ្ធិចូលរួម** ប្រជុំមហាសន្និបាតភាគហ៊ុនិកតាមកាលកំណត់។
- ភាគហ៊ុនិកដែលធ្វើការ **ទិញ** មូលបត្រកម្មសិទ្ធិរបស់ខ្លួន នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៦ **នឹងមិនមានសិទ្ធិចូលរួម** ប្រជុំមហាសន្និបាតភាគហ៊ុនិកទេ។
- ក្នុងករណីដែលភាគហ៊ុនិកពុំអាចចូលរួម និងបោះឆ្នោតតាមកាលបរិច្ឆេទ និងពេលវេលាកំណត់ ភាគហ៊ុនិកអាចធ្វើការ ផ្តល់សិទ្ធិប្រទានទៅឱ្យអ្នកតំណាងណាម្នាក់ ដើម្បីចូលរួម និងបោះឆ្នោតជំនួស ។

- ភាគហ៊ុនិកនឹងត្រូវចាត់ទុកថា បានបោះបង់សិទ្ធិចូលរួមមហាសន្និបាតភាគហ៊ុនិក ប្រសិនបើមិនបានបញ្ជាក់ការចូលរួម ឬមិនបានផ្តល់លិខិតប្រគល់សិទ្ធិជូនភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ តាមពេលវេលាកំណត់ដូចខាងក្រោម។
- ភាគហ៊ុនិកត្រូវបញ្ជាក់ពីការចូលរួមកិច្ចប្រជុំរបស់ខ្លួនដោយផ្ទាល់ ឬអ្នកទទួលសិទ្ធរបស់ខ្លួន និងត្រូវផ្ញើរលិខិតប្រគល់សិទ្ធិ មកភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ របស់ធនាគារ អេស៊ីលីដា តាមរយៈមធ្យោបាយអេឡិចត្រូនិក យ៉ាងយូរត្រឹមថ្ងៃទី ០៣ ខែ មេសា ឆ្នាំ២០២៦ វេលាម៉ោង ៥:០០នាទីល្ងាច ។

សម្រាប់ព័ត៌មានបន្ថែម សូមធ្វើការទំនាក់ទំនងទៅកាន់ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្ររបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី និងលេខទំនាក់ទំនង ដូចខាងក្រោម៖

១. អ្នកស្រី សំរិទ្ធ វណ្ណីបុប្ផារដ្ឋ
- ➢ ទូរស័ព្ទ: (+៨៥៥) ៧០ ៥០០ ៣៧៧
- ➢ អ៊ីម៉ែល: samreth.vannybopharath@acledabank.com.kh

២. លោក កែន រិទ្ធពុទ្ធា
- ➢ ទូរស័ព្ទ: (+៨៥៥) ១៥ ៨០០ ៦៦៣
- ➢ អ៊ីម៉ែល: ken.rithputhea@acledabank.com.kh

៣. កញ្ញា ចាន់ ទេពកញ្ញា
- ➢ ទូរស័ព្ទ: (+៨៥៥) ១៦ ២៩៥ ៤៣២
- ➢ អ៊ីម៉ែល: op.rtp@acledabank.com.kh

សេចក្តីដូចបានជម្រាបជូនខាងលើ សូមមេត្តាជ្រាបជាព័ត៌មាន។

ភ្នំពេញ, ថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៦
ក្រុមហ៊ុន ពីកាសូ ស៊ីធី ហ្គាដិន ឌីវេឡុបមិុន ម.ក

ក្រុមហ៊ុន ពីកាសូ ស៊ីធី ហ្គាដិន ឌីវេឡុបមិុន ម.ក
PICASSO CITY GARDEN DEVELOPMENT PLC.
KINGDOM OF CAMBODIA